

# គម្រោងលើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព

## គ្រួសារប្រពៃ កូនវៃឆ្លាត

អន្តរាគមន៍សុខភាព ដើម្បីជួយគាំទ្រដល់ស្ត្រីមានផ្ទៃពោះ និង ស្ត្រីជាម្តាយក្រោយសម្រាល ឲ្យមានសុខភាពកាន់តែប្រសើរ

### បរិបទ

រយៈពេល ១000 ថ្ងៃដំបូង មានសារៈសំខាន់បំផុតក្នុងជីវិតរបស់កុមារ ហើយមានឥទ្ធិពលលើសុខភាពក្នុងពេលអនាគតពេញមួយជីវិតរបស់ពួកគេ ។ មូលដ្ឋានគ្រឹះនៃការចាប់ផ្តើមជីវិតប្រកបដោយសុខុមាលភាព គឺអាហារូបត្ថម្ភសម្រាប់ទាំងម្តាយនិងកូន ។ អាហារូបត្ថម្ភរបស់ម្តាយមានសារៈសំខាន់សម្រាប់ម្តាយខ្លួនឯង ដើម្បីធានាថា គាត់មានសុខភាពល្អគ្រប់គ្រាន់ដើម្បីថែទាំខ្លួនឯង និងកូនរបស់គាត់ ។ អាហារូបត្ថម្ភក៏មានសារៈសំខាន់ផងដែរ សម្រាប់ទារកដែលបៅដោះ និងទទួលបានការថែទាំពីម្តាយ ក្នុងអំឡុងពេលដ៏សំខាន់បំផុតនេះ ។ នៅក្នុងផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ របស់ក្រសួងសុខាភិបាល គោលដៅអភិវឌ្ឍន៍សុខភាពទីមួយគឺ ៖ "លើកកម្ពស់សុខភាពបន្តពូជ និងកាត់បន្ថយអត្រាស្លាប់របស់មាតា ទារក និងកុមារ និងកង្វះអាហារូបត្ថម្ភក្នុងចំណោមស្ត្រី និងកុមារតូចៗ" ។

កង្វះអាហារូបត្ថម្ភគឺជាបញ្ហាមួយចំពោះកុមារអាយុក្រោម ៥ ឆ្នាំនៅក្នុងគ្រួសារដែលមានប្រាក់ចំណូលទាប នៅក្នុងជនបទនៃប្រទេសកម្ពុជា ។ បញ្ហានេះបណ្តាលឱ្យកុមារមានភាពក្រេះក្រិន មានជំងឺ ការឆ្លងរោគផ្សេងៗ ហានិភ័យនៃការស្លាប់កាន់តែច្រើន ការយឺតយ៉ាវក្នុងការអភិវឌ្ឍសតិបញ្ញា លទ្ធផលសិក្សាមិនល្អនៅក្នុងសាលារៀន និងការបោះបង់ចោលការសិក្សា ។ នៅទូទាំងប្រទេស ៤២% នៃកុមារអាយុក្រោម ៥ ឆ្នាំ មានបញ្ហាក្រេះក្រិន ។ អត្រាក្រេះក្រិននៅតំបន់ទីប្រជុំជននិងជនបទ មានភាពខុសគ្នា ដោយក្នុងនោះ ៣៤% នៃកុមារនៅជនបទ មានបញ្ហាក្រិន ។ អត្រាប្រេវ៉ាឡង់នៃបញ្ហាក្រេះក្រិន មានកម្រិតខ្ពស់ ទាំងក្នុងខេត្តកំពង់ឆ្នាំង (៤៣%) និងកំពង់ចាម (៣៤%)។

ស្របតាមគោលដៅអភិវឌ្ឍន៍សុខភាពជាតិ គម្រោងលើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព (PHB) ដែលផ្តល់មូលនិធិដោយ USAID កំពុងតែរៀបចំបង្កើនសកម្មភាពផ្លាស់ប្តូរឥរិយាបថសង្គម (SBC) ដើម្បីគាំទ្រដល់ការលើកកម្ពស់សុខភាពម្តាយ និងទារក ។

**ក្រុមគោលដៅ ៖**

ក្រុមគោលដៅចម្បង ៖ ស្ត្រីមានផ្ទៃពោះ អំឡុងពេល៨ខែ និងស្ត្រីជាម្តាយក្រោយសម្រាល

ក្រុមគោលដៅបន្ទាប់បន្សំ ៖ អ្នកមានឥទ្ធិពល ដូចជាយាយ ឪពុក អ្នកមើលថែក្មេង និងមិត្តភក្តិ ព្រមទាំងធ្មប

**ការអនុវត្ត ៖**

- ណែនាំអោយស្ត្រីដែលមានផ្ទៃពោះចាប់ពី៨ខែ ឲ្យស្គាល់ពីកម្មវិធីសារជាសំលេងតាមទូរស័ព្ទ (IVRs) ស្តីអំពីការគាំពារសុខភាពមាតានិងទារក
- ផ្តល់ការណែនាំឲ្យសុខភាពទាំងម្តាយនិងកូន កាន់តែប្រសើរឡើង

**គោលបំណងឥរិយាបថ ៖**

១) បំបៅដោះកូនដោយទឹកដោះម្តាយ ក្នុងម៉ោងដំបូងនៃកំណើត
២) បំបៅដោះកូនដោយទឹកដោះម្តាយ តែមួយមុខគត់ រយៈពេល៦ខែដំបូងនៃអាយុ
៣) បន្តការបំបៅដោះកូនដោយទឹកដោះម្តាយ រហូតដល់កូនអាយុ២ឆ្នាំ
៤) ទៅមូលដ្ឋានសុខាភិបាល ជាមួយទារក ដើម្បីទទួលការថែទាំក្រោយសម្រាល យ៉ាងតិច៤ដង ក្នុងរយៈពេល ១០សប្តាហ៍ក្រោយពេលសម្រាល
៥) ផ្តល់របបអាហារបន្ថែមដល់កុមារពីអាយុ៦ខែ ដល់២៣ខែ ដែលមានបរិមាណសមស្របតាមអាយុ ដោយមានអាហារចម្រុះ

## យុទ្ធសាស្ត្រ និងសម្ភារជំនួយ

| ចំណេះដឹង | ការពិចារណា | ការសន្ទនា | ការចូលរួម |
|---|---|---|---|
| ឃើញផ្ទាំងរូបភាពនៅមណ្ឌលសុខភាព | ឮពីឆ្មបអំឡុងពេលពិនិត្យផ្ទៃពោះ<br>• អត្ថប្រយោជន៍<br>• ដំណើរការ | • ឆ្មបជួយចុះឈ្មោះកម្មវិធី IVR ឲ្យស្ត្រីមានផ្ទៃពោះ ដោយទូរស័ព្ទទៅលេខ ដែលមាននៅលើផ្ទាំងរូបភាព<br>• ស្ត្រីទទួលការហៅត្រលប់មកវិញភ្លាមៗ ដើម្បីបញ្ជាក់ពីការចុះឈ្មោះ | • ស្ត្រីទទួលសារចំនួន២៨ ក្រោយសម្រាល<br>• ជម្រើសនៃសារ:<br>○ ស្តាប់ម្តងទៀតបាន<br>○ ចាកចេញពីកម្មវិធី |








*សារជាសំលេងតាមទូរស័ព្ទ (IVRs):* ដើម្បីផ្តល់ព័ត៌មាន និងរំលឹកម្តាយឱ្យអនុវត្តឥរិយាបថសំខាន់ៗចំនួន ៣-៤

*ផ្ទាំងរូបភាព (ចុះឈ្មោះក្រោយពេលសម្រាល):* ដើម្បីលើកទឹកចិត្តស្ត្រីឱ្យសួរឆ្មបអំពីអត្ថប្រយោជន៍ដើម្បីជួយពួកគេចុះឈ្មោះ មុនពេលចាកចេញពីមន្ទីរពេទ្យជាមួយទារករបស់ពួកគេ ។

*ស្ទីយ័រទូរស័ព្ទ:* ដើម្បីរំលឹកម្តាយអំពី IVRs និងឆ្លើយទូរស័ព្ទ ក៏ដូចជា ប្រាប់មិត្តភក្តិពួកគេឱ្យមកជួបឆ្មបដើម្បីចុះឈ្មោះ ។

*សៀវភៅណែនាំអំពីការចុះឈ្មោះ:* ដើម្បីជួយឆ្មបចុះឈ្មោះម្តាយដើម្បីទទួលសេវា IVR ។

### ការតាមដាន វាយតម្លៃ និងសិក្សា

គម្រោង PHB ធ្វើការតាមដានការធ្វើអន្តរាគមន៍នេះ និងសកម្មភាពផ្លាស់ប្តូរឥរិយាបថដទៃទៀតរបស់គម្រោង ដោយប្រមូលទិន្នន័យសកម្មភាព ក្រុមគោលដៅ និងសម្ភារៈដែលបានចែកចាយ ព្រមទាំងព័ត៌មានអំពីចំណេះដឹង និងឥរិយាបថ របស់អត្ថាគាហក មុននិងក្រោយបានទំនាក់ទំនងជាមួយសកម្មភាពរបស់គម្រោង។ លទ្ធផលនិងមេរៀនដែលទទួលបាន នឹងយកទៅប្រើដើម្បីអនុវត្តគម្រោងបន្ត និងធ្វើអោយកាន់តែមានភាពប្រសើរឡើង នូវសកម្មភាពផ្លាស់ប្តូឥរិយាបថរបស់គម្រោង ព្រមទាំងចែកចាយជាប្រចាំ ទៅសហគមន៍នៃអ្នកធ្វើការផ្នែកផ្លាស់ប្តូរឥរិយាបថ។

*អន្តរាគមន៍នេះធ្វើឡើងក្រោមការគាំទ្រពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក និងមន្ទីរសុខាភិបាលខេត្ត ព្រមទាំងអង្គការពាក់ព័ន្ធផ្សេងៗទៀត។*

***ព័ត៌មានទំនាក់ទំនង ៖***
Jim Malster, នាយកគម្រោង
អង្គការអន្តរជាតិបំរើសុខភាពប្រជាជន (PSI)
jmalster@psi.org
https://www.facebook.com/CambodiaPHBActivity



# CAMBODIA PROMOTING HEALTHY BEHAVIORS (PHB) ACTIVITY

## GOOD FAMILIES RAISE SMART KIDS

AN INTERVENTION TO SUPPORT TO PREGNANT WOMEN AND NEW MOTHERS ON HOW TO HELP THEM AND THEIR BABIES BE HEALTHY AND THRIVE

### Context

The first 1000 days are critical in a child's life and have an impact on their life-long future health. Foundational to a healthy start in life is the nutrition of both mother and child. Maternal nutrition is important for the mother herself, to ensure she is healthy enough to care for herself and her child. It is also important for the baby, who will breastfeed and receive care from the mother throughout this critical time. In the Ministry of Health Strategic Plan 2016-2020, the first health development goal is to: "Improve reproductive health, and reduce maternal, newborn and child mortality and malnutrition among women and youth children."

Malnutrition is a problem for children under five in low-income households in rural Cambodia. It causes stunting, illnesses, infections, increased risk of mortality, delayed cognitive development, poor performance in school, and fewer years in school. Nationally, 42% of children under 5 are stunted. There is an urban/rural divide - with 34% of rural children being stunted. The prevalence is high in both Kampong Chhnang (43%) and Kampong Cham (34%).

In line with the national health development goal, USAID-funded Promoting Health Behaviors Project (PHB) is designing a social and behavior change (SBC) activity to support improved health for mothers and their babies.

**Target Audiences:**

Primary Audiences: Mothers from 8 months pregnant to 24 months postpartum

Secondary Audiences: A postpartum mother's influencers: Mother (grandmother), husband, healthcare workers, and midwife

**Implementation:**

- Introduce interactive voice response (IVR) service to women who are 8-months pregnant during their antenatal care (ANC) classes.
- Help pregnant women in ANC classes to sign up for IVR messages that they will receive up to and after delivery.

**Behavioral Objectives:**

The SBC activity aims to promote 5 key behaviors:

1. Breastfeed newborns within the first hour of birth
2. Exclusive breastfeeding for the first 6 months
3. Continue breastfeeding for 2 years
4. Visit health facility (public or private) for at least 4 PNC check-ups with baby within 10 weeks of delivery
5. Introduce complementary feeding for children 6-23 months with age-appropriate quantity and diversity of foods and snacks

## Strategy and Tools

| AWARENESS | CONSIDERATION | CONVERSION | ENGAGEMENT |
|---|---|---|---|
| See posters in a health care center | Hear from a midwife during ANC<br>• benefits<br>• how it works | • Midwife helps mother to sign up for IVR services by calling the number on the poster<br>• Mother receives registration confirmation call straight away | • Mother receives 28 post-birth IVRs<br>• IVR options:<br>  ○ listen again (repeat messages)<br>  ○ unsubscribe to the service |








*IVRs:* to inform and remind mothers to perform 3-4 key behaviors

*Poster (pre-birth sign up):* to encourage women to ask the midwife about the benefits and to help women sign up during their ANC visit

*Poster (post-birth sign up):* to encourage women to ask their midwife about the benefits and to help them sign up before leaving the hospital with their baby

*Phone sticker:* to remind mothers of the IVRs and pick up calls as well as tell their friends to visit midwives to sign up

*Sign up guide:* to help midwives sign mothers up to the IVR service

### Monitoring, Evaluation and Learning

PHB conducts ongoing monitoring of this and all its SBC activities, capturing data in terms of activities implemented, people reached, and materials distributed, as well as information on beneficiaries' knowledge, attitudes, and behavior prior to and after exposure to PHBs activities. Results and lessons learned are used to iterate and improve the SBC activities, and are regularly shared with the wider SBC community.

*This intervention is made possible with support from the National Maternal and Child Health Centre (NMCHC), Provincial Health Departments and other stakeholders.*

***Contact information:***
*Jim Malster, Chief of Party,*
*Population Services International (PSI)*
*jmalster@psi.org*
*https://www.facebook.com/CambodiaPHBActivity*